# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

### សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
### ស្តីពី
### ករណីវិជ្ជមានកូវីដ-១៩ ថ្មី ០១នាក់ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ សម្រាប់អ្នកដំណើរចូលមកប្រទេសកម្ពុជា នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ មានដូចខាងក្រោម៖

- ត្រឹមម៉ោង១៨:០០នាទីនៃថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ លទ្ធផលតេស្តសំណាកអ្នកដំណើរទទួលបានពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បង្ហាញថាមានអ្នកវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០១នាក់ ជាបុរសជនជាតិខ្មែរអាយុ ២៦ឆ្នាំ មានទីលំនៅនៅឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត
- បុរសរូបនេះ ជាអ្នកដំណើរវិលត្រឡប់មកពីប្រទេសហ្វីលីពីន បន្តជើងហោះហើរពីសាធារណរដ្ឋកូរ៉េ បានមកដល់កម្ពុជានៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ២២:០០នាទី
- អ្នកដំណើរសរុបចូលកម្ពុជាមាន ៦៣នាក់ (ស្រី ១៤នាក់ និងប្រុស ៤៩នាក់) ដែលមានជនជាតិកូរ៉េ ២៣នាក់ (ស្រី ៣នាក់) បុរសជនជាតិបែលហ្ស៊ិក ១នាក់ បុរសជនជាតិតៃវ៉ាន់ ១នាក់ បុរសជនជាតិ ហូឡង់ ១នាក់ ជនជាតិជប៉ុន ៣នាក់ (ស្រី ១នាក់) និងជនជាតិខ្មែរ ៣៤នាក់ (ស្រី ១០នាក់) មានការត្រួតពិនិត្យសុខភាពដោយក្រុមគ្រូពេទ្យ និងបានដាក់ឲ្យនៅរង់ចាំកន្លែងធ្វើចត្តាឡីស័កនៅជិតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅពេលមកដល់រាជធានីភ្នំពេញភ្លាម ហើយបានយកវត្ថុសំណាកទៅធ្វើវិភាគទាំងអស់ ដែលជាលទ្ធផលបង្ហាញថា មានវិជ្ជមានវីរុសកូវីដ-១៩ លើបុរសជនជាតិខ្មែរម្នាក់ខាងលើនេះ។
- ក្រសួងសុខាភិបាល បានបញ្ជូនបុរសរូបនេះ ទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រួចហើយ។ ដោយឡែក អ្នកដំណើរទាំង ៦២នាក់ទៀត ត្រូវបន្តធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ ដើម្បីតាមដានសុខភាពតាមវិធានការសុខាភិបាលជាចាំបាច់។

ក្រសួងសុខាភិបាល សូមបន្តអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ត្រូវបន្តអនុវត្តវិធានការការពារខ្លួនជាចាំបាច់នៅក្នុងដំណាក់កាលប្រយុទ្ធនឹងជំងឺកូវីដ-១៩ នេះ ដើម្បីការពារការចម្លងវីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ហើយក្រសួងសុខាភិបាល នឹងបន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ [illegible] / ៨៨៤ ៩០៩

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨៤៥ ៩២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០